ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ១៨០១ ប្រក

# ប្រ កា ស

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រី រាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សំ រេ ច

**ប្រការ ១** : ត្រូវបានតែងតាំងមុខតំណែងមន្ត្រីរាជការចំនួន ០៣រូប ជា**អភិបាលរង** នៃគណៈអភិបាលស្រុកស្នួល ខេត្តក្រចេះ ដូចមាននាមខាងក្រោម :

| | |
|---|---|
| ១- លោក **ម៉ែន វណ្ណា** | អភិបាលរងស្រុក |
| ២- លោកស្រី **ខៀវ សុផៃ** | អភិបាលរងស្រុក |
| ៣- លោក **តឹក គ្រាង** | អភិបាលរងស្រុក |

**ប្រការ ២** : ក្នុងរយៈពេលមកបំពេញភារកិច្ចថ្មីខាងលើ លោកស្រី **ខៀវ សុផៃ** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**ប្រការ ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤** : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និង ហិរញ្ញវត្ថុ អភិបាលខេត្តក្រចេះ ប្រធាននាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និង សាមីខ្លួន ដែលមានឈ្មោះក្នុងប្រការ១ខាងលើ ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងអប់រំ យុវជន និង កីឡា
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ (ដើម្បីអនុវត្ត)
- ឯកសារ— កាលប្បវត្តិ